# កម្រងសិទ្ធិនៃអ្នកបោះឆ្នោត

1. **អ្នកមានសិទ្ធិបោះឆ្នោត បើសិនអ្នក ជាអ្នកបោះឆ្នោតបានចុះឈ្មោះមានឯកសិទ្ធិ។**
   អ្នកបោះឆ្នោតបានចុះឈ្មោះមានឯកសិទ្ធិ មានន័យថាជាសញ្ជាតិសហរដ្ឋ ដែលជាអ្នកមូលដ្ឋាននៅក្នុងរដ្ឋនេះ ដែលមានអាយុតិចបំផុត 18 ឆ្នាំ ហើយមិនជាប់គុក ឬមិនឋិតក្នុងការសាកល្បងសំរាប់ការជាប់ទោសនៃបទឧក្រិដ្ឋ ហើយក៏ជាអ្នកបានចុះឈ្មោះដើម្បីបោះឆ្នោត នៅឯទីលំនៅបច្ចុប្បន្នរបស់ខ្លួន។
2. **អ្នកមានសិទ្ធិបោះឆ្នោត នូវសន្លឹកឆ្នោតបណ្ដោះអាសន្ន បើសិនឈ្មោះរបស់អ្នកមិនបានចុះរាយនៅក្នុងបញ្ជីបោះឆ្នោត។**
3. **អ្នកមានសិទ្ធិបោះឆ្នោត បើសិនអ្នកមានវត្តមាន និងឈរតម្រង់ជួរនៅកន្លែងបោះឆ្នោត នៅមុនពេលជិតដល់វេលាបិទបោះឆ្នោត។**
4. **អ្នកមានសិទ្ធិបោះឆ្នោត នូវសន្លឹកឆ្នោតសំងាត់ ដោយរួចចាកពីការកំញើញ។**
5. **អ្នកមានសិទ្ធិទទួលសន្លឹកឆ្នោតថ្មី បើសិនជានៅមុនពេលអ្នកបោះឆ្នោត អ្នកជឿថាអ្នកបានធ្វើដោយភាន់ច្រឡំ។**
   បើសិនជានៅពេលណាមួយ មុនពេលអ្នកបោះឆ្នោតជាផ្ដាច់ព្រ័ត្រ អ្នកមានអារម្មណ៍ថាអ្នកបានធ្វើដោយភាន់ច្រឡំ អ្នកមានសិទ្ធិដូរសន្លឹកឆ្នោតដែលខូច យកសន្លឹកឆ្នោតថ្មីមួយទៀត។ អ្នកបោះឆ្នោតបោះឆ្នោត-តាមសំបុត្រ ក៏អាចនឹងស្នើសុំ និងទទួលសន្លឹកឆ្នោតថ្មីបានដែរ បើសិនគេផ្ញើសន្លឹកឆ្នោតដែលខូចត្រឡប់ទៅឲ្យមន្ត្រីការបោះឆ្នោតវិញ នៅមុនពេលបិទពិធីបោះឆ្នោត នៅថ្ងៃបោះឆ្នោត។
6. **អ្នកមានសិទ្ធិទទួលជំនួយក្នុងការបោះឆ្នោតរបស់អ្នក បើសិនអ្នកពុំអាចបោះឆ្នោតដោយគ្មានជំនួយ។**
7. **អ្នកមានសិទ្ធិផ្ញើសន្លឹកឆ្នោត បោះឆ្នោត-តាមសំបុត្រ ដែលបានបំពេញចប់ ត្រឡប់ទៅមណ្ឌលណាមួយនៅក្នុងខោនធី។**
8. **អ្នកមានសិទ្ធិទទួលសំភារៈការបោះឆ្នោត ជាភាសាមួយទៀត បើសិនមានប្រជាជនគ្រប់គ្រាន់នៅក្នុងមណ្ឌលរបស់អ្នក ដើម្បីធានាផលិតកម្ម។**
9. **អ្នកមានសិទ្ធិសួរសំណួរ អំពីទំរង់ការបោះឆ្នោត និងសង្កេតមើលដំណើរការបោះឆ្នោត។**
   អ្នកមានសិទ្ធិសួរសំណួរ ទៅគណៈកម្មការមណ្ឌល និងមន្ត្រីការបោះឆ្នោត ស្ដីអំពីទំរង់ការបោះឆ្នោត និងទទួលចំឡើយ ឬបានណែនាំឲ្យជួបមន្ត្រីត្រឹមត្រូវ សំរាប់ចំឡើយ។ តែជាយ៉ាងណាមិញ បើសិនការសួរឥតឈប់ឈរ ដែលរំខានដល់ការបំពេញភារៈកិច្ចរបស់គេ នោះគណៈកម្មការ ឬមន្ត្រីការបោះឆ្នោត អាចនឹងឈប់តបឆ្លើយចំពោះសំណួរទាំងនោះ។
10. **អ្នកមានសិទ្ធិរាយការណ៍ អំពីសកម្មភាពខុសច្បាប់ ឬការក្លែងបន្លំអ្វីមួយ ទៅមន្ត្រីការបោះឆ្នោត ឬការិយាល័យរបស់រដ្ឋលេខាធិការ។**

## កំណត់ពិសេស

- កន្លែងបោះឆ្នោតគឺបើកពីម៉ោង 7:00 ព្រឹក ដល់ម៉ោង 8:00 យប់ នៅថ្ងៃបានបង្ហាញនៅក្នុងសន្លឹកឆ្នោតគំរូដែលបានបិទប្រកាស។
- សេចក្ដីណែនាំជាក់លាក់ អំពីរបៀបបោះឆ្នោត រួមទាំងរបៀបបោះឆ្នោតនូវសន្លឹកឆ្នោតបណ្ដោះអាសន្ន អាចទទួលបានពីអ្នកធ្វើការនៅកន្លែងបោះឆ្នោត ឬដោយអានព័ត៌មានដែលបានផ្ញើទៅឲ្យអ្នក ដោយមន្ត្រីការបោះឆ្នោតតាមមូលដ្ឋានរបស់អ្នក។
- បើសិនអ្នកជាអ្នកបោះឆ្នោតបានចុះឈ្មោះថ្មោងថ្មី អ្នកនឹងបានសូមឲ្យផ្ដល់អត្តសញ្ញាណត្រឹមត្រូវ ឬឯកសារផ្សេងទៀត ស្របទៅតាមច្បាប់រដ្ឋបាលសហព័ន្ធ។ ប៉ុន្តែសូមចំណាំថា បុគ្គលគ្រប់ៗរូប សុទ្ធតែមានសិទ្ធិបោះឆ្នោតនូវសន្លឹកឆ្នោតបណ្ដោះអាសន្ន ទោះបើគាត់មិនផ្ដល់ឯកសារក៏ដោយ។
- វាជាការល្មើសនឹងច្បាប់ ដើម្បីបង្ហាញខ្លួនឯងថាមានសិទ្ធិបោះឆ្នោត លុះត្រាតែអ្នកស្របតាមសេចក្ដីតម្រូវទាំងអស់ដើម្បីបោះឆ្នោតនៅក្រោមច្បាប់រដ្ឋបាលសហព័ន្ធ និងរដ្ឋ។
- វាជាការល្មើសនឹងច្បាប់ ដើម្បីធ្វើអុកឡុកដល់ឧបករណ៍បោះឆ្នោត។




**បើសិនអ្នកជឿថា អ្នកត្រូវបានបដិសេធនូវសិទ្ធិទាំងនេះ ឬបើសិនអ្នកដឹងនូវការក្លែងបន្លំណាមួយនៃការបោះឆ្នោត ឬការប្រព្រឹត្តិល្មើស សូមទូរស័ព្ទទៅរដ្ឋលេខាធិការតាមលេខសំងាត់ឥតចេញថ្លៃ**

**លេខពិសេសអ្នកបោះឆ្នោត តាមលេខ (888) 345-4917។**